# អ្វីដែលត្រូវយល់ដឹង អំពី ថ្នាំសម្រាប់ ជំងឺ COVID-19

**ឥឡូវនេះ អាចរកថ្នាំ** ដើម្បីទប់ស្កាត់ និងព្យាបាលជំងឺ COVID-19 បានហើយ។ ជាមួយនឹងថ្នាំបង្ការ ដូសជំរុញ ការធ្វើតេស្ត និងការពាក់ម៉ាស់ ថ្នាំទាំងនេះគឺជាវិធីមួយទៀតដែលយើងអាចការពារខ្លួនអ្នក និងសហគមន៍របស់យើងឱ្យមានសុវត្ថិភាពពីជំងឺ COVID-19 បាន។






## មានផ្តល់ជូនតាមវេជ្ជបញ្ជាតែប៉ុណ្ណោះ

**ពិគ្រោះជាមួយអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក** ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ឬគិតថាថ្នាំទាំងនេះត្រូវសម្រាប់អ្នក។ និយាយអំពីការព្រួយបារម្ភអំពីសុខភាពណាមួយ និងថ្នាំដែលអ្នកកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនឹងប្រាប់អ្នកថា ប្រសិនបើអ្នកមានសិទ្ធិទទួលបានថ្នាំនោះ និងពន្យល់អំពីជម្រើសផ្សេងៗរបស់អ្នក។

ប្រសិនបើ អ្នកមិនមានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទេ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលសុខភាពសាធារណៈ តាមរយៈលេខទូរស័ព្ទ 1-833-540-0473។

## ចុះការចំណាយវិញ?

**ថ្នាំគឺមិនគិតថ្លៃទេ** ប៉ុន្តែប្រហែលជាអាចមានការគិតថ្លៃពីអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព។

- ប្រសិនបើអ្នកមាន **ធានារ៉ាប់រងឯកជន** សូមពិនិត្យមើលផែនការរបស់អ្នកដើម្បីដឹងថាតើផែនការនេះគ្របដណ្តប់ទៅលើការចំណាយទាំងអស់ឬទេ។
- ប្រសិនបើអ្នក **មិនមានធានារ៉ាប់រងឯកជនទេ** សូមសាកសួរឱសថស្ថាន មន្ទីរពេទ្យ ឬ ការិយាល័យគ្រូពេទ្យអំពីថ្លៃសេវាកម្មផ្សេងទៀត។
- សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលសុខភាពសាធារណៈ តាមរយៈទូរស័ព្ទលេខ 1-833-540-0473 ដើម្បីទទួលបានការថែទាំដែលឥតគិតថ្លៃ។



កម្មវិធី Medicare និង Medicaid ទទួលរ៉ាប់រងទៅលើការចំណាយទាំងអស់។

ថ្នាំទាំងនេះគឺ **មិនមែនជាការជំនួសថ្នាំបង្ការជំងឺ** COVID-19 នោះទេ ហើយ **ក៏មិនផ្លាស់ប្តូរសេចក្តីណែនាំស្តីពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែក និងការធ្វើចត្តាឡីស័ក** នោះដែរ។ ប្រសិនបើអ្នកមានសិទ្ធិទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 អ្នកគួរតែទទួលចាក់ថ្នាំបង្ការឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

# ថ្នាំសម្រាប់ទប់ស្កាត់ជំងឺ COVID-19



**ប្រសិនបើអ្នកមិនអាចទទួលចាក់ថ្នាំបង្ការជំងឺ** COVID-19 បានដោយសារហេតុផលវេជ្ជសាស្ត្រនានា អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអាចចេញវេជ្ជបញ្ជាឱ្យទទួលថ្នាំដែលអាចការពារអ្នកប្រសើរជាងមុន ពីការកើតមានជំងឺ COVID-19 កម្រិតធ្ងន់ធ្ងរ។

ថ្នាំសម្រាប់ទប់ស្កាត់ជំងឺអាចរកបានសម្រាប់មនុស្សដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ហើយដែលមិនអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 បានដោយសារហេតុផលវេជ្ជសាស្ត្រនានា ឬអ្នកដែលមិនអាចឆ្លើយតបបានល្អចំពោះថ្នាំបង្ការ ពីព្រោះពួកគេមានប្រព័ន្ធភាពស៊ាំខ្សោយ ដោយសារស្ថានភាពជំងឺ ឬការព្យាបាលមួយ។



## អ្វីដែលត្រូវធ្វើ៖

**ពិគ្រោះជាមួយអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក** ប្រសិនបើអ្នកគិតថាថ្នាំទាំងនេះត្រូវសម្រាប់អ្នក។ និយាយអំពីការព្រួយបារម្ភអំពីសុខភាពណាមួយ និងថ្នាំដែលអ្នកកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។



# ថ្នាំសម្រាប់ព្យាបាលជំងឺ COVID-19



**ប្រសិនបើអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមានសម្រាប់ជំងឺ** COVID-19 ហើយប្រឈមនឹងហានិភ័យខ្ពស់ក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរមានថ្នាំសម្រាប់ព្យាបាលដែលអាចទទួលបាន។ស្ថានភាពវេជ្ជសាស្ត្រដែលប្រឈមនឹងហានិភ័យខ្ពស់មួយចំនួន រួមមាន៖

- មាន/ធ្លាប់មានជំងឺមហារីក
- មានជំងឺទឹកនោមផ្អែម
- មាន/ធ្លាប់មានបញ្ហាបេះដូង
- មានជំងឺតម្រងនោម ថ្លើម ឬសួតរ៉ាំរ៉ៃ
- មានផ្ទៃពោះ
- គឺលើសទម្ងន់ ឬធាត់ខ្លាំង



ការព្យាបាលដោយលេបនិងចាក់ថ្នាំ អាចរកបានសម្រាប់មនុស្សដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ហើយអាចទប់ស្កាត់អ្នកពីការចូលទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ប្រសិនបើអ្នកប្រើប្រាស់វាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីចាប់ផ្តើមមានរោគសញ្ញា៖

- ក្អក
- គ្រុនក្តៅ ឬគ្រុនរងា
- ពិបាកដកដង្ហើម
- អស់កម្លាំង
- ឈឺក្បាល



## អ្វីដែលត្រូវធ្វើ៖

**សូមទូរស័ព្ទទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពឱ្យបានឆាប់ៗ** ហើយសាកសួរអំពីថ្នាំសម្រាប់ព្យាបាល ប្រសិនបើអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមានសម្រាប់ជំងឺ COVID-19 និងមានរោគសញ្ញានានា។

**ឬប្រើប្រាស់កម្មវិធី <u>ធ្វើតេស្តដើម្បីព្យាបាល</u>** (Test to Treat) ដើម្បីធ្វើតេស្តនៅទីតាំងផ្ទាល់ ។ប្រសិនបើអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមាន អ្នកអាចទទួលបានថ្នាំក្នុងអំឡុងពេលនៅទីតាំងនោះតែម្តង។

លើសពីនេះទៅទៀត អ្នកអាចទាក់ទងទៅសេវាកម្មថែទាំសុខភាពពីចម្ងាយរបស់សុខភាពសាធារណៈ (Public Health Telehealth) តាមរយៈទូរស័ព្ទលេខ **1-833-540-0473** សម្រាប់ការវាយតម្លៃនិងការព្យាបាល។ប្រសិនបើអ្នកបានធ្វើតេស្តទទួលលទ្ធផលវិជ្ជមានរួចហើយ អ្នកអាចស្នើសុំឱ្យផ្ញើថ្នាំទៅអ្នកដោយផ្ទាល់ ឬផ្ញើទៅទីតាំង <u>Test to Treat</u> ក្នុងតំបន់ជិតអ្នកដើម្បីទៅទទួលយកនៅទីនោះ។